**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :......០៤៣/២១.......**ក.ប**/ស.ជ.ណ.២.៧

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យអនុវត្តសាកល្បងនូវរបបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម សម្រាប់រោងចក្រ សហគ្រាស ផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរ និងកាបូប

ក្នុងគោលបំណងធ្វើទំនើបកម្មប្រព័ន្ធអធិការកិច្ចការងារ, ធ្វើអធិការការកិច្ចការងារដោយផ្អែកលើកម្រិតហានិភ័យរបស់រោងចក្រ សហគ្រាស, កាត់បន្ថយបន្ទុករបស់រោងចក្រ សហគ្រាសក្នុងការទទួលប្រតិភូអធិការកិច្ចការងារក្នុងបរិបទកូវីដ-១៩ ក៏ដូចជាអនុវត្តតាមផែនការសកម្មភាពរួមរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងដាក់ឱ្យអនុវត្តសាកល្បងនូវរបបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម សម្រាប់រោងចក្រ សហគ្រាស ផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរ និងកាបូប ចាប់ពីថ្ងៃទី១ ខែតុលា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ តទៅ តាមរយៈគេហទំព័រ https://sicms.mlvt.gov.kh/។

សម្រាប់ព័ត៌មានបន្ថែម ម្ចាស់ ឬនាយករោងចក្រ សហគ្រាស អាចសួរព័ត៌មានបន្ថែមក្នុងក្រុម "សម្រាប់និយោជក" តាមរយៈតេឡេក្រាម https://t.me/EmployerChat។

ក្នុងករណីម្ចាស់ ឬនាយករោងចក្រ សហគ្រាស ដែលខកខានក្នុងការធ្វើស្វ័យប្រកាសសាកល្បងនេះ ត្រូវទទួលការដាក់ពិន័យតាមច្បាប់ជាធរមាន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយករោងចក្រ សហគ្រាស អនុវត្តបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ សុក្រ ៧រោច ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**